GOLDWELL
CAPITAL

# ក្រុមហ៊ុន  ហ្គោលវែល ខាភីថល ឯ.ក
GOLDWELL CAPITAL CO., LTD.

# កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ
**CLIENT AGREEMENT FOR DERIVATIVES TRADING**

ឈ្មោះអតិថិជន៖..............................................................លេខគណនី៖....................................

ឈ្មោះភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ៖..........................................លេខកូដសម្គាល់៖ ......................

កម្រៃជើងសា៖.........................................................................................................................

អាគារ  ហ្គោលដេន ថាវើ  ជាន់ទីផ្ទាល់ដី ការិយាល័យលេខ១៥៨-១៦៦ ផ្លូវ ២១៥
សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ទូរស័ព្ទទំនាក់ទំនង៖ ០២៣ ៨៨៨ ៧៧៨ អ៊ីម៉ែល៖ enquiry@goldwellcap.com

កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទនេះ (**កិច្ចព្រមព្រៀង**) ធ្វើនៅរាជធានីភ្នំពេញ៖
**រវាង៖**

(១) ក្រុមហ៊ុន ហ្គោលវែល ខាភីថល ឯ.ក ដែលមានអាសយដ្ឋាននៅអាគារ ហ្គោលដេន ថាវើ ជាន់ផ្ទាល់ដី ការិយាល័យលេខ ១៥៨-១៦៦ ផ្លូវ ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ជាឈ្មួញជើងសាឧបករណ៍និស្សន្ទទទួលបាន អាជ្ញាបណ្ណលេខ ០០៩/អ.ជ./ឈ.ឧ. ចេញដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) តំណាងដោយភ្នាក់ងារជើងសាឧបករណ៍និស្សន្ទឈ្មោះ ............................................................................ លេខអាជ្ញាបណ្ណភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ............................................................ តទៅហៅកាត់ថា ក្រុមហ៊ុន

**និង**

(២) ឈ្មោះ............................................................................ ដែលមានអាសយដ្ឋាន ............................................................................................................................ លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន................................. លេខបញ្ជីពាណិជ្ជកម្ម (ករណីជាស្ថាប័ន) ..............................ថ្ងៃទី...........ខែ..................ឆ្នាំ........... តទៅហៅកាត់ថា អតិថិជន

**ភាគីទាំងពីរបានព្រមព្រៀងដូចតទៅ៖**

**ប្រការ ១៖ និយមន័យ**

**ឧបករណ៍និស្សន្ទ** (Derivatives Instrument) ៖ សំដៅដល់កិច្ចសន្យាលើគម្លាតថ្លៃ (Contract For Difference) នៃឧបករណ៍ហិរញ្ញវត្ថុដើម ដែលចេញពីមូលបត្រកម្មសិទ្ធិ មូលបត្របំណុល សន្ទស្សន៍ លោហធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ កសិផល រូបិយប័ណ្ណ រួមទាំងគម្រោងការពារថ្លៃដើម (Principal Protected Scheme) ជាដើម និងដែលត្រូវបានជួញដូរក្នុងទីផ្សារ។ ឧបករណ៍និស្សន្ទទាំងនេះគឺជាឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។

**អាជីវកម្មជើងសាឧបករណ៍និស្សន្ទ (Derivatives Brokerage Business)៖** សំដៅដល់អាជីវកម្មផ្តល់សេវា សម្រាប់ការជួញដូរឧបករណ៍និស្សន្ទក្នុងនាមជាភ្នាក់ងាររបស់អតិថិជនខ្លួន។

**ក្រុមហ៊ុនសមភាគីកណ្តាល** (Central Counterparty)៖ សំដៅដល់ក្រុមហ៊ុនដែលធ្វើជាដៃគូផ្ទាល់ចំពោះរាល់កិច្ចសន្យាជួញដូរលើឧបករណ៍និស្សន្ទមួយ ឬច្រើនពោលគឺក្លាយជាភាគីអ្នកទិញចំពោះរាល់អ្នកលក់ និងក្លាយជាភាគីអ្នកលក់ចំពោះរាល់អ្នកទិញ។

**គម្លាតថ្លៃ** (Spread)៖ សំដៅដល់គម្លាតរវាងថ្លៃទិញ និងថ្លៃលក់នៃផលិតផល។

**ច្បាប់** (Law)៖ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ឈ្មួញជើងសាឧបករណ៍និស្សន្ទ** (Derivatives Broker)៖ សំដៅដល់ក្រុមហ៊ុនដែលត្រូវទទួលបានអាជ្ញាបណ្ណ ឬក្រុមហ៊ុនមូលបត្រដែលត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក ដើម្បីធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ។

**ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ** (Derivatives Representative)៖ សំដៅដល់រូបវន្តបុគ្គល ដែលត្រូវទទួលអាជ្ញាបណ្ណ ពីអគ្គនាយកនៃ គ.ម.ក ដើម្បីបើក និងគ្រប់គ្រងគណនីឲ្យអតិថិជន និងផ្តល់សេវាផ្សេងទៀតក្នុងនាមឈ្មួញជើងសាឧបករណ៍និស្សន្ទ។

**ម៉ាជីន** (Margin)៖ សំដៅលើការតម្កល់ប្រាក់ ដែលតម្រូវដោយក្រុមហ៊ុនធ្វើឡើងដោយអតិថិជនជាមួយក្រុមហ៊ុនដើម្បីធានាការអនុវត្តកាតព្វកិច្ចរបស់អតិថិជនទៅតាមខចែង និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលទាំងម៉ាជីនដំបូង និងម៉ាជីនរក្សា។

**ម៉ាជីនដំបូង** (Initial Margin)៖ សំដៅដល់ទំហំសាច់ប្រាក់ដំបូង ដែលត្រូវបានកំណត់គិតជាភាគរយនៃទំហំវិនិយោគសរុបដែលអតិថិជនត្រូវដាក់តម្កល់ជាចាំបាច់ក្នុងគណនីមុនធ្វើការជួញដូរ។

**ម៉ាជីនខល** (Margin Call)៖ សំដៅដល់ការតម្រូវឲ្យអតិថិជនដាក់សាច់ប្រាក់បំពេញបន្ថែមទៅក្នុងគណនីរបស់ខ្លួនដើម្បីឲ្យសមតុល្យគណនីកើនឡើងដល់លក្ខខណ្ឌតម្រូវ។

**ម៉ាជីនទូទាត់** (Liquidation Margin)៖ សំដៅដល់កម្រិតម៉ាជីនដែលការជួញដូរត្រូវបានទូទាត់ជាស្វ័យប្រវត្តិនៅពេលដែលមិនមានការបំពេញបន្ថែមសាច់ប្រាក់ទៅក្នុងគណនីតាមម៉ាជីនខល។

**ទំហំជួញដូរអតិបរមា/អប្បបរមា** ( Maximum/Minimum Trade Size)៖ សំដៅដល់ចំនួនឯកតាជួញដូរ (Lot) ក្នុងកម្រិតខ្ពស់បំផុត/ទាបបំផុតដែលត្រូវបានកំណត់ និងអនុញ្ញាតឲ្យធ្វើការជួញដូរ។

**ឡេវើរ៉េច**(Leverage)៖ សំដៅដល់កម្រិតដែលអនុញ្ញាតឲ្យអតិថិជនអាចធ្វើការជួញដូរបាន លើសពីទំហំសាច់ប្រាក់ជាក់ស្តែងដែល ខ្លួនមាន។

**អនុក្រឹត្យ** (Anukret)៖ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ឯកតាជួញដូរ** (Lot)៖ សំដៅដល់ចំនួនឯកតានៃផលិតផលដែលបានកំណត់សម្រាប់ការជួញដូរ។

**ឯកតានៃបម្រែបម្រួលថ្លៃ** (Pip)៖ សំដៅដល់ឯកតាបម្រែបម្រួលថ្លៃរបស់ផលិតផលក្នុងកម្រិតតូចបំផុតដែលត្រូវបានកំណត់ជាស្តង់ដា។

**ការជួញដូរមិនប្រក្រតី** (Abnormal Transaction)៖ មានន័យថាជាវិធីសាស្ត្រជួញដូរ ឧបករណ៍ មធ្យោបាយ តម្រូវ ឬការចាត់ចែង ដែលធ្វើឡើងដោយអតិថិជន កើតឡើងដោយសារការជួញដូរ ឬស៊េរីនៃការជួញដូរដែលក្រុមហ៊ុនយល់ឃើញ និងសម្រេច ដោយមិនចាំបាច់ពិគ្រោះយោបល់ជាមួយអតិថិជនជាមុន អាចធ្វើឲ្យប៉ះពាល់ ឬបានប៉ះពាល់ដល់ស្ថេរភាព ភាពនឹងនរ និង/ឬ ហានិភ័យទីផ្សារក្រុមហ៊ុន។ បើមិនមានលក្ខខណ្ឌណាចែងផ្សេងពីកិច្ចព្រមព្រៀងទេ នោះក្រុមហ៊ុនមានសិទ្ធិជាឯកតោភាគី និងសិទ្ធិផ្តាច់មុខ ពិចារណា ឬកំណត់ថា ការជួញដូរ ឬស៊េរីនៃការជួញដូរណាមួយ ទោះបាន ឬមិនបានប្រព្រឹត្ត គ្រប់គ្រង ឬបង្កើតឡើងដោយអតិថិជនក្តី អាចចាត់ទុកថា ជាការជួញដូរខុសប្រក្រតី ដូចដែលបានឲ្យនិយមន័យនេះនៃកិច្ចព្រមព្រៀងនេះ។

**សេវាអនឡាញ** (On-line Services)៖ សំដៅលើសេវាជួញដូរតាមប្រព័ន្ធអ៊ីនធើណេត ដែលផ្តល់ដោយក្រុមហ៊ុនទៅកាន់អតិថិជន ដើម្បីសម្រួលដល់ការជួញដូររបស់អតិថិជន។

**ប្រការ ២៖ លក្ខខណ្ឌទូទៅ**

**២.១.** អតិថិជនព្រមព្រៀងឲ្យក្រុមហ៊ុនបម្រើសេវាកម្មជាភ្នាក់ងាររបស់អតិថិជន និងមានសិទ្ធិក្នុងការធ្វើសកម្មភាពដែលទាក់ទងនឹងការជួញដូរឧបករណ៍និស្សន្ទតាមការបញ្ជាទិញ-លក់របស់អតិថិជន។ អតិថិជនព្រមព្រៀងអនុវត្តកាតព្វកិច្ចនានាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុនក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**២.២.** ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ ក្នុងគណនីអតិថិជន ក្នុងនាមអតិថិជនក្នុងទម្រង់ជាគណនីឆន្ទានុសិទ្ធិឡើយ។

**២.៣.** ក្រុមហ៊ុនធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណពី គ.ម.ក. ក្នុងការផ្តល់សេវាកម្មជូនអតិថិជន។

**២.៤.** ភាគីទាំងពីរទទួលស្គាល់ និងព្រមព្រៀងថាការបង់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗឲ្យក្រុមហ៊ុនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់តាមតារាង **(១)** និងអាចប្រែប្រួលតាមការកំណត់របស់ គ.ម.ក.។ ក្រុមហ៊ុនអាចធ្វើបច្ចុប្បន្នកម្មតារាង **(១)** នៅពេលមានការផ្លាស់ប្តូរលាភការ និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរអំពីការផ្លាស់ប្តូរនោះ។ ការតម្លើងលាភការដែលត្រូវបង់ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះមាន សុពលភាពអនុវត្តលុះត្រាតែកិច្ចព្រមព្រៀងនេះបានធ្វើបច្ចុប្បន្នកម្ម ហើយអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រម។

**២.៥.** អតិថិជនបានអាន និងយល់ច្បាស់ពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងលក្ខខណ្ឌទូទៅនៃការជួញដូរឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុន និងធានាថាអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងលក្ខខណ្ឌទូទៅនេះ។

**២.៦.** អតិថិជនយល់ព្រមផ្តល់ជូនក្រុមហ៊ុននូវ៖

ក. ព័ត៌មានស្តីពីអត្តសញ្ញាណពិតប្រាកដរបស់អតិថិជន និងអ្នកទទួលផលប្រយោជន៍ពីអតិថិជន។

ខ. គោលដៅនៃការជួញដូររបស់អតិថិជន។

គ.ព័ត៌មានស្តីពីការជួញដូររបស់អតិថិជនក្នុងក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេង និងព័ត៌មានស្តីពីការជួញដូរឧបករណ៍និស្សន្ទដែលអតិថិជនកំពុងជួញដូរ។

ឃ.នៅពេលដែលអតិថិជនធ្វើការបញ្ជូនបញ្ជាការជួញដូរសម្រាប់បុគ្គលផ្សេងទៀត អតិថិជនយល់ព្រមផ្តល់ព័ត៌មានដូចមានចែងក្នុងចំណុច (ក) (ខ) និង (គ) នៃចំណុច ២.៦ ខាងលើរបស់បុគ្គលនោះ។

**២.៧.** ភាគីទាំងពីរព្រមព្រៀងថា ការជួញដូរឧបករណ៍និស្សន្ទត្រូវធ្វើឡើងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**២.៨.** ក្រុមហ៊ុនត្រូវផ្តល់ជូនអតិថិជននូវរបាយការណ៍ស្តីពីប្រតិបត្តិការនៃការជួញដូរឧបករណ៍និស្សន្ទ ព្រមទាំងស្ថានភាព និងបម្រែបម្រួលនៃសមតុល្យសាច់ប្រាក់របស់អតិថិជនក្នុងថ្ងៃជួញដូរ បន្ទាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការរបស់អតិថិជន និងត្រូវរៀបចំរបាយការណ៍ជួញដូរឧបករណ៍និស្សន្ទដើម្បីជូនដំណឹងពីសមតុល្យសាច់ប្រាក់ ស្ថានភាពជួញដូរឧបករណ៍និស្សន្ទ និងម៉ាជីនរបស់អតិថិជន ដើម្បីឲ្យអតិថិជនបានដឹង និង/ឬផ្ទៀងផ្ទាត់ជាមួយប្រព័ន្ធដែលបង្កើតឡើងដោយក្រុមហ៊ុនក្នុងអំឡុងម៉ោងធ្វើការ។ ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍នេះជូនអតិថិជនតាមរយៈលាយលក្ខណ៍អក្សរ សារអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត ដោយមានការយល់ព្រមពីអតិថិជនជាមុន។

**ប្រការ ៣៖ ការជួញដូរឧបករណ៍និស្សន្ទ**

**៣.១.** អតិថិជនយល់ព្រមដាក់តម្កល់ប្រាក់ ឬទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់ជានាមុនពេលធ្វើការជួញដូរឧបករណ៍និស្សន្ទម្តងៗ។

**៣.២.**ដើម្បីដាក់បញ្ជាលក់ ឬទិញឧបករណ៍និស្សន្ទតាមរយៈកិច្ចព្រមព្រៀងនេះ អតិថិជនត្រូវយល់ដឹងឲ្យច្បាស់ពីប្រភេទផ្សេងៗ និងលក្ខខណ្ឌនៃបញ្ជាលក់ ឬទិញដែលកំណត់ដោយក្រុមហ៊ុនសមាជិកកណ្តាលអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។

**៣.៣.** បញ្ជាលក់ ឬទិញអាចធ្វើឡើងតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ សម្លេង សារអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។ នៅពេលទទួលបញ្ជាពីអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុង

ទម្រង់ជាឯកសារជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីផ្ទៀងផ្ទាត់បញ្ជារបស់អតិថិជន។ កំណត់ត្រានៃបញ្ជានោះត្រូវបង្ហាញឈ្មោះរបស់អតិថិជន, លេខគណនីជួញដូរ, ព័ត៌មានលម្អិតនៃបញ្ជានិងកាលបរិច្ឆេទ និងពេលវេលានៃការដាក់បញ្ជាជាដើម។ ករណីដាក់បញ្ជាលក់ ឬទិញឧបករណ៍និស្សន្ទធ្វើឡើងតាមរយៈទូរស័ព្ទ អតិថិជន យល់ព្រមអនុញ្ញាតឲ្យក្រុមហ៊ុនថតសម្លេងទាក់ទងនឹងបញ្ជាលក់ ឬទិញតាមរយៈទូរស័ព្ទ ដើម្បីឲ្យក្រុមហ៊ុនទុកជាភស្តុតាង។

៣.៤. ក្រុមហ៊ុនត្រូវធានាឲ្យមាននូវយន្តការប្រកបដោយប្រសិទ្ធិភាពក្នុងការទទួលបញ្ជាលក់ ឬទិញពីអតិថិជន។

៣.៥. ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានដល់អតិថិជនអំពីហានិភ័យ ដែលអាចកើតមានពាក់ព័ន្ធនឹងការដាក់បញ្ជាលក់ ឬទិញ និងទទួលខុសត្រូវលើហានិភ័យនៃការរអាក់រអួលប្រព័ន្ធទូរស័ព្ទ អ៊ីនធើណេត ឬប្រព័ន្ធជួញដូរផ្ទៃក្នុងរបស់ក្រុមហ៊ុនក្នុងពេលទទួលបញ្ជាលក់ ឬទិញពីអតិថិជន។ ក្រុមហ៊ុនមិនទទួលខុសត្រូវលើហានិភ័យនៃការរអាក់រអួលនៃប្រព័ន្ធទូរសព្ទ អ៊ីនធើណែត ឬប្រព័ន្ធជួញដូរដែលបង្កឡើងដោយប្រធានស័ក្តិដូចជាសង្គ្រាម ភាពចលាចល ការបះបោរ ការធ្វើអន្តរាគមន៍នៃយោធា អស្ថិរភាពនយោបាយ ការបង្ក្រាបរបស់កងកម្លាំងនគរបាល ការបំផ្លិចបំផ្លាញដោយចេតនា ការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ រដ្ឋប្រហារ កុប្បកម្ម ទឹកជំនន់ រញ្ជួយដី រន្ទះបាញ់ ខ្យល់ព្យុះ ភ្លើងឆេះ និងជំងឺរាតត្បាត។

៣.៦. ក្រុមហ៊ុនធានាកាត់បន្ថយជាអតិបរមានូវហានិភ័យដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការបញ្ជាលក់ ឬទិញ។

៣.៧. ក្រុមហ៊ុនត្រូវជូនដំណឹងភ្លាមដល់អតិថិជន ក្នុងករណីក្រុមហ៊ុនដឹងថា មានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាលក់ ឬទិញ ប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជាលក់ ឬទិញ។

៣.៨. អតិថិជនត្រូវទទួលស្គាល់ថាបានសិក្សា និងយល់ដឹងច្បាស់លាស់អំពីហានិភ័យដែលអាចកើតមានឡើងក្នុងការដាក់បញ្ជាលក់ ឬទិញដែលក្រុមហ៊ុនបានផ្តល់ព័ត៌មាន។

៣.៩.អតិថិជនត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុនក្នុងករណីអតិថិជនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាលក់ ឬទិញប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជាលក់ ឬទិញ។

៣.១០. អតិថិជនទទួលស្គាល់ និងយល់ព្រមថាការទិញ ឬលក់ឧបករណ៍និស្សន្ទតាមរយៈឈ្មួញជើងសារឧបករណ៍និស្សន្ទ គឺជាការទិញ ឬលក់រវាងអតិថិជនជាមួយក្រុមហ៊ុនសមាគីកណ្តាល ដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យាដែលក្រុមហ៊ុនជាភ្នាក់ងារ។

៣១១. អតិថិជនព្រមព្រៀងថា អតិថិជនគឺជាអ្នកដែលមានសិទ្ធិតែម្នាក់គត់ក្នុងការប្រើប្រាស់លេខគណនី និងភ្ជាប់ទៅលេខកូដសម្ងាត់ និងសេវាអនឡាញ ឬតាមរយៈ ទូរស័ព្ទ ឬដោយមធ្យោបាយផ្សេងទៀតដែលកំណត់ និងទទួលយកដោយក្រុមហ៊ុន។ អតិថិជនត្រូវរក្សាលេខកូដសម្ងាត់ជាការសម្ងាត់បំផុត និងមិនត្រូវបង្ហាញលេខកូដសម្ងាត់ទៅបុគ្គលណាម្នាក់ឡើយ ទោះស្ថិតក្នុងកាលៈទេសណាក៏ដោយ។

៣.១២. អតិថិជនយល់ព្រមបង់ថ្លៃនានាដែលក្រុមហ៊ុនតម្រូវឲ្យអតិថិជនបង់ សម្រាប់ការប្រើប្រាស់សេវាអនឡាញ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ដោយ និងទទួលយកដោយក្រុមហ៊ុន។

៣.១៣. អតិថិជនយល់ព្រមពិនិត្យរាល់ការណែនាំ មុននឹងចូលប្រើប្រាស់សេវាអនឡាញ ឬទូរស័ព្ទ ឬមធ្យោបាយណាមួយដែលកំណត់ និងទទួលយកដោយក្រុមហ៊ុនដោយហេតុថាការបញ្ជារបស់អតិថិជនដែលបានដាក់ហើយ មិនអាចលុបចោលបានទេ។ អតិថិជនអាចស្នើសុំជាលាយលក្ខណ៍អក្សរ ដើម្បីលុបចោល ឬកែប្រែការបញ្ជារបស់អតិថិជន ប៉ុន្តែក្រុមហ៊ុនមិនមានកាតព្វកិច្ចត្រូវតែទទួលយកការស្នើសុំនោះទេ។ អតិថិជនទទួលស្គាល់ថា ការបញ្ជាអាចលុបចោល ឬកែប្រែបានមុនពេលអនុវត្តតែប៉ុណ្ណោះ។

៣.១៤. នៅពេលក្រុមហ៊ុនបានទទួលបញ្ជាពីអតិថិជនតាមរយៈសេវាអនឡាញ ឬតាមរយៈទូរស័ព្ទ ឬតាមមធ្យោបាយផ្សេងទៀតដែលកំណត់ និងដែលអាចទទួលយកបានដោយក្រុមហ៊ុនៈ

(ក) ក្រុមហ៊ុននឹងអនុវត្តតាមការបញ្ជាតាមតម្លៃដែលដកស្រង់ចេញពីសេវាអនឡាញ ឬតាមទូរស័ព្ទផ្ទាល់ ឬតាមមធ្យោបាយផ្សេងទៀតដែលកំណត់ដោយ និងទទួលយកដោយក្រុមហ៊ុន ក្នុងអំឡុងពេលដែលកំណត់ច្បាស់លាស់ ពីការទទួលបាននូវបញ្ជាដោយក្រុមហ៊ុន។ ឬ

(ខ) នៅពេលដែលអតិថិជនកំណត់តម្លៃច្បាស់ហើយ ក្រុមហ៊ុននឹងចាប់ផ្តើមអនុវត្តតាមការបញ្ជាភ្លាមនៅពេលដែលតម្លៃដែលបាន ដកស្រង់ចេញពីសេវាអនឡាញ ឬតាមទូរស័ព្ទផ្ទាល់ ឬតាមមធ្យោបាយផ្សេងទៀតដែលកំណត់ដោយក្រុមហ៊ុន និងអាចទទួលយកដោយក្រុមហ៊ុន បានមកដល់ ឬទទួលបានតម្លៃដែលកំណត់នោះ ហើយតម្លៃដែលត្រូវអនុវត្តតាមគឺជាតម្លៃដែលបានដកស្រង់ចេញពីសេវាអនឡាញ ឬតាម ទូរស័ព្ទផ្ទាល់ ឬតាមមធ្យោបាយដែលបានកំណត់ និងទទួលយកដោយក្រុមហ៊ុនក្នុងពេលវេលាមួយដែលបានកំណត់ប្រតិបត្តិការច្បាស់លាស់ ដែលមិនអាចកំណត់ភាពខ្ពស់ជាង ឬទាបជាងតម្លៃដែលបានកំណត់ឡើយ។

៣.១៥. អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមដល់ក្រុមហ៊ុនប្រសិនបើៈ

(ក) អតិថិជនមិនបានទទួលការបញ្ជាក់ពីក្រុមហ៊ុនតាមរយៈសារអេឡិចត្រូនិកអំពីការទទួលស្គាល់ថាបានទទួលបញ្ជាពីអតិថិជនដែលត្រូវបានធ្វើឡើងតាមរយៈសេវាអនឡាញ ឬទូរស័ព្ទ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ និងដែលទទួលយកបានដោយក្រុមហ៊ុន។

(ខ) អតិថិជនបានទទួលការបញ្ជាក់ពីក្រុមហ៊ុនតាមរយៈសារអេឡិចត្រូនិកអំពីការទទួលស្គាល់ថាបានទទួលបញ្ជាពីអតិថិជន ដែលអតិថិជនមិនបានធ្វើការបញ្ជា។

(គ) អតិថិជនបានដឹងថាអ្នកដទៃបានប្រើប្រាស់លេខកូដសម្ងាត់របស់ខ្លួនដោយមិនមានការអនុញ្ញាត។

(ឃ) អតិថិជនមានការលំបាកក្នុងការប្រើប្រាស់សេវាអនឡាញ ឬទូរស័ព្ទ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ និងដែលអាចទទួលយកបានដោយក្រុមហ៊ុន។

**៣.១៦.** អតិថិជនទទួលស្គាល់ និងយល់ព្រមថាអតិថិជនទទួលខុសត្រូវទាំងអស់លើការបញ្ជាទាំងឡាយដែលធ្វើឡើងតាមរយៈសេវា អនឡាញ ឬទូរស័ព្ទ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ និងដែលអាចទទួលយកបានដោយក្រុមហ៊ុនដោយប្រើប្រាស់លេខកូដសម្ងាត់ដោយអតិថិជនផ្ទាល់ ឬដោយអ្នកដទៃដែលទទួលបានការអនុញ្ញាត ឬដែលមិនទទួលបានការអនុញ្ញាត ឬដោយភ្នាក់ងារជើងសាឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុន លើកលែងតែបញ្ជាបង្កឡើងដោយភ្នាក់ងារជើងសាឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនដែលស្ថិតក្នុងការទទួលខុសត្រូវរបស់ក្រុមហ៊ុន។

**៣.១៧.** អតិថិជនទទួលស្គាល់ និងយល់ព្រមថាក្រុមហ៊ុនគឺជាម្ចាស់នៃសេវាអនឡាញ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ និងដែលអាចទទួលយកបានដោយក្រុមហ៊ុន។ អតិថិជនមិនត្រូវធ្វើឲ្យមានបញ្ហា ព្យាយាមបំផ្លាញ ឬផ្លាស់ប្តូរផ្នែករឹង (hardware) និង/ឬផ្នែកទន់ (Software) នៃសេវាអនឡាញ ឬមធ្យោបាយផ្សេងទៀតដែលបានកំណត់ និងទទួលយកដោយក្រុមហ៊ុន និងមិនត្រូវផ្តល់សិទ្ធិបន្តលើការប្រើប្រាស់សេវា អនឡាញ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ និងដែលអាចទទួលយកបានដោយក្រុមហ៊ុន ឬប្រើប្រាស់សេវាអនឡាញផ្ទុយពីគោលបំណងដែលបានកំណត់។ អតិថិជនត្រូវជូនដំណឹងទៅក្រុមហ៊ុនភ្លាម ប្រសិនបើអតិថិជនបានដឹងថាសកម្មភាពណាមួយដូចបានរៀបរាប់ក្នុងកថាខណ្ឌនេះបាន ឬកំពុងប្រព្រឹត្តដោយបុគ្គលណាមួយ។ ក្រុមហ៊ុនមានសិទ្ធិក្នុងការលុបចោលប្រតិបត្តិការជួញដូរនៅពេលក្រុមហ៊ុនសង្ស័យ ឬមានហេតុផលជឿជាក់ថាប្រតិបត្តិការជួញដូរទាំងនោះធ្វើឡើងដោយប្រើប្រាស់ប្រព័ន្ធ ឬកម្មវិធីជួញដូរ ឬវិធីសាស្ត្រផ្សេងទៀតដែលប៉ះពាល់ដល់ស្ថេរភាពនៃប្រព័ន្ធជួញដូររបស់ក្រុមហ៊ុន។

**៣.១៨.** អតិថិជនទទួលស្គាល់ថា ក្រុមហ៊ុនមិនមានការធានាពីការទាន់ពេលវេលា ភាពតាមលំដាប់លំដោយ និរន្តរភាព ភាពឆាប់រហ័ស ឬភាពពេញលេញនៃព័ត៌មានក្នុងសេវាអនឡាញ ឬទូរស័ព្ទ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ និងដែលអាចទទួលយកបានដោយក្រុមហ៊ុន និងពុំមានការផ្តល់អនុសាសន៍ណែនាំ ឬការគាំទ្រដែលកើតចេញពីការសន្និដ្ឋានលើព័ត៌មានដែលបានផ្តល់។

## ប្រការ ៤៖ តម្លៃ និងគម្លាតថ្លៃឧបករណ៍និស្សន្ទ

**៤.១.** រាល់តម្លៃឧបករណ៍និស្សន្ទ ត្រូវបានកំណត់ដោយក្រុមហ៊ុនសមភាគីកណ្តាល ដោយយោងតាមតម្លៃបច្ចុប្បន្នដែលដកចេញពីប្រភពផ្សេងៗគ្នាជាច្រើនដែលក្រុមហ៊ុនសមភាគីកណ្តាលយល់ឃើញថាត្រឹមត្រូវសម្រាប់ទីផ្សារឧបករណ៍និស្សន្ទ។

**៤.២.** ក្រុមហ៊ុនមានសិទ្ធិកែប្រែ គម្លាតថ្លៃនៃឧបករណ៍និស្សន្ទអនុលោមតាមវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនសមភាគីកណ្តាល។

**៤.៣.** ក្រុមហ៊ុនធានាថា តម្លៃ និងគម្លាតថ្លៃឧបករណ៍និស្សន្ទដែលដាក់ចេញមានភាពយុត្តិធម៌ និងសមហេតុផល។

## ប្រការ ៥៖ គោលការណ៍នៃការបញ្ជូនបញ្ជា និងការដាក់បញ្ជាទិញ ឬលក់

**៥.១.** ការបញ្ជាទិញ ឬលក់របស់អតិថិជន ត្រូវផ្តល់ឲ្យដោយអតិថិជនក្នុងលក្ខខណ្ឌមួយដែលច្បាស់លាស់ និងត្រូវធ្វើឡើងដោយអតិថិជនផ្ទាល់ជាមួយនឹងក្រុមហ៊ុនតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ សម្លេង សារអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលបានកំណត់ និងអាចទទួលយកបានដោយក្រុមហ៊ុន។

**៥.២.** ក្រុមហ៊ុនអាចបដិសេធទទួល និង/ឬធ្វើប្រតិបត្តិការតាមការបញ្ជាណាមួយរបស់អតិថិជនប្រសិនបើ៖

១. បញ្ជានោះមិនបានគោរពទៅតាមច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធ វិធានប្រតិបត្តិការ និងកិច្ចព្រមព្រៀងនេះ។

២. បញ្ជានោះបានផុតកំណត់ ឬត្រូវបានលុបចោល។

៣. អតិថិជនមិនមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើប្រតិបត្តិការតាមបញ្ជានោះ។

**៥.៣.** ក្រុមហ៊ុនត្រូវចាត់ទុកថាបានទទួលបញ្ជារបស់អតិថិជន នៅពេលអតិថិជនទទួលបានការបញ្ជាក់បានទទួលបញ្ជាពីក្រុមហ៊ុន។

**៥.៤.** ក្រុមហ៊ុនត្រូវបង្ហាញ និងពន្យល់ខ្លឹមសារនៃវិធានប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទដល់អតិថិជនមុនចុះកិច្ចព្រមព្រៀងនេះជាមួយអតិថិជន។

**៥.៥.** អតិថិជនត្រូវទទួលស្គាល់ថាបានសិក្សា និងយល់ដឹងច្បាស់លាស់អំពីវិធានប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទដែលបង្ហាញ និងពន្យល់ដោយក្រុមហ៊ុន។

## ប្រការ ៦៖ ការទូទាត់ និងថ្លៃសេវារដ្ឋបាល

រូបិយប័ណ្ណក្នុងការទូទាត់សម្រាប់ការជួញដូរឧបករណ៍និស្សន្ទត្រូវគិតជាដុល្លារអាមេរិក។ អត្រាប្តូរប្រាក់រវាងដុល្លារអាមេរិក និងរូបិយប័ណ្ណដទៃទៀតត្រូវកំណត់ដោយក្រុមហ៊ុនដោយយោងតាមអត្រាទីផ្សារទូទៅ។

## ប្រការ ៧៖ ម៉ាជីន

៧.១. អតិថិជនយល់ព្រមដាក់តម្កល់សាច់ប្រាក់ជាមួយក្រុមហ៊ុនក្នុងគោលបំណងធ្វើការជួញដូរឧបករណ៍និស្សន្ទទៅតាមម៉ាជីនដែលកំណត់ដោយក្រុមហ៊ុន អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន ក្នុងទំហំសាច់ប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល ឬ ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក លើកលែងតែអតិថិជននោះជាវិនិយោគិនគុណវុឌ្ឍិដែលបំពេញលក្ខខណ្ឌតាមច្បាប់ និងប្បញ្ញត្តិជាធរមាន ។

៧.២. ក្រុមហ៊ុនត្រូវដាក់សាច់ប្រាក់អតិថិជនក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទដាច់ដោយឡែកពីគណនីរបស់ក្រុមហ៊ុននៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក.។

៧.៣. ក្រុមហ៊ុននឹងគណនាតម្លៃនៃឧបករណ៍និស្សន្ទនៅក្នុងគណនីរបស់អតិថិជន និងកែតម្រូវម៉ាជីនដែលបានដាក់តម្កល់ដោយអតិថិជននៅក្រុមហ៊ុន យ៉ាងយូរត្រឹមចុងថ្ងៃជួញដូរដើម្បីឲ្យកម្រិតម៉ាជីននៅក្នុងគណនីរបស់អតិថិជនស្របតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។

៧.៤. អតិថិជនយល់ព្រមអនុវត្តម៉ាជីនរក្សាដែលកំណត់ដោយក្រុមហ៊ុនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។ ប្រសិនកម្រិតម៉ាជីនរបស់អតិថិជនទាបជាងម៉ាជីនរក្សា អតិថិជនត្រូវពិនិត្យពីភាពគ្រប់គ្រាន់នៃកម្រិតម៉ាជីន ដូចដែលក្រុមហ៊ុនបានជូនដំណឹងទៅអតិថិជន តាមរយៈមធ្យោបាយដែលទទួលយល់ព្រមជាមុនពីអតិថិជនដូចជា លិខិតជាលាយលក្ខណ៍អក្សរ ទូរសារ ទូរស័ព្ទ អ៊ីម៉ែល ឬមធ្យោបាយអេឡិច- ត្រូនិកផ្សេងៗទៀត និងអតិថិជនត្រូវដាក់សាច់ប្រាក់បំពេញបន្ថែម ដើម្បីឲ្យកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនមិនទាបជាងម៉ាជីនដំបូង។ អតិថិជនត្រូវដាក់សាច់ប្រាក់បំពេញបន្ថែមម៉ាជីននៅក្នុងអំឡុងពេលជាក់លាក់ណាមួយដែលកំណត់ដោយក្រុមហ៊ុន។

៧.៥. អតិថិជនអាចដកសាច់ប្រាក់ដែលបានដាក់តម្កល់ក្នុងករណីកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនខ្ពស់ជាងម៉ាជីនដំបូង។

៧.៦. ករណីក្រុមហ៊ុនមិនបានទទួលសាច់ប្រាក់បន្ថែមពីអតិថិជនក្នុងរយៈពេលដែលបានកំណត់ ក្រុមហ៊ុនមានសិទ្ធិដូចខាងក្រោម៖

ក. បដិសេធការដាក់បញ្ជាលក់ ឬទិញបន្ថែមរបស់អតិថិជន។

ខ. បិទរាល់ស្ថានភាពជួញដូរឧបករណ៍និស្សន្ទទាំងអស់ ឬមួយផ្នែករបស់អតិថិជន។

៧.៧. ក្រុមហ៊ុនមិនត្រូវដកសាច់ប្រាក់របស់អតិថិជនឡើយ លើកលែងករណីដូចខាងក្រោម៖

ក. ក្រុមហ៊ុនធ្វើការទូទាត់ឲ្យបុគ្គលណាមួយដែលមានសិទ្ធិក្នុងក្របខ័ណ្ឌនៃការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជន។

ខ. ក្រុមហ៊ុនធ្វើការទូទាត់ថ្លៃសេវា កម្រៃជើងសា និងបន្ទុកចំណាយផ្សេងទៀតដែលអតិថិជនត្រូវបង់។

គ. ក្រុមហ៊ុនធ្វើការទូទាត់ឲ្យបុគ្គល ឬគណនីផ្សេងយោងតាមការស្នើសុំរបស់អតិថិជនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

ឃ. ក្រុមហ៊ុនធ្វើការទូទាត់ ឬដកសាច់ប្រាក់ដែលតម្រូវដោយ គ.ម.ក. ឬ ច្បាប់។

៧.៨. អតិថិជនត្រូវផ្តល់ព័ត៌មាន និង/ឬ ឯកសារដែលតម្រូវដោយក្រុមហ៊ុន និងស្របតាមច្បាប់ និងវិធានផ្សេងៗដែលមានជាធរមាន ដើម្បីឲ្យក្រុមហ៊ុនអាចបើកគណនីជួញដូរឲ្យអតិថិជន។ រាល់ព័ត៌មាន និងឯកសារដែលផ្តល់ដោយអតិថិជន ត្រូវពិតប្រាកដ និងត្រឹមត្រូវ។ អតិថិជនត្រូវជូនដំណឹងដល់ក្រុមហ៊ុនអំពីការផ្លាស់ប្តូរព័ត៌មាន និង/ឬឯកសារដែលអតិថិជនបានផ្តល់ឲ្យក្រុមហ៊ុន។ ករណីអតិថិជនមិនបានបំពេញកាតព្វកិច្ចទាំងនេះ ក្រុមហ៊ុនមានសិទ្ធិបិទគណនីជួញដូររបស់អតិថិជន។

៧.៩.

(ក) អតិថិជនត្រូវទទួលខុសត្រូវទាំងស្រុង លើការខាតបង់ និងការចំណាយផ្សេងៗដែល កើតឡើងដោយសារការខកខានរបស់អតិថិជនក្នុងការដាក់សាច់ប្រាក់បំពេញបន្ថែមចូលក្នុងគណនីជួញដូរតាមការតម្រូវ។

(ខ) នៅពេលក្រុមហ៊ុនកែប្រែលក្ខខណ្ឌតម្រូវម៉ាជីនដំបូង ឬម៉ាជីនរក្សាអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន អតិថិជនត្រូវគោរពតាមលក្ខខណ្ឌតម្រូវថ្មីនេះ។ អតិថិជនយល់ព្រមរក្សាកម្រិតម៉ាជីនតាមលក្ខខណ្ឌតម្រូវថ្មីនេះ។

៧.១០. ប្រសិនបើក្រុមហ៊ុនដឹង ឬរកឃើញពីការជួញដូរខុសប្រក្រតី ក្រុមហ៊ុនមានសិទ្ធិក្នុងការសម្រេចជាឯកតោភាគី និងផ្តាច់មុខ បើកការស៊ើបអង្កេតភ្លាម លុបចោល និងកែតម្រូវការជួញដូរខុសប្រក្រតីឲ្យត្រឹមត្រូវវិញ ដោយមិនចាំបាច់ជូនដំណឹងជាមុន ឬផ្តល់សំណងដល់ អតិថិជនឡើយដោយយោងតាមកិច្ចព្រមព្រៀង។ បន្ទាប់ពីមានការកើតឡើង ឬការរកឃើញនៃការជួញដូរខុសប្រក្រតី ក្រុមហ៊ុនមានសិទ្ធិជាឯកតោភាគី និងផ្តាច់មុខដើម្បីផ្អាកការផ្តល់សេវាកម្មរបស់ក្រុមហ៊ុនដល់អតិថិជន ឬចាត់ និងអនុវត្តវិធានការណាមួយចំពោះអតិថិជន អនុលោមតាមកិច្ចព្រមព្រៀងនេះ ។ ដោយមិនប៉ះពាល់ទៅលើដំណើរការទូទៅណាមួយ អតិថិជនបង្ហាញការយល់ព្រម និងទទួលស្គាល់ថា បើមានការប្រព្រឹត្តផ្ទុយពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ (១) ក្រុមហ៊ុនមានសិទ្ធិជាឯកតោភាគី និងផ្តាច់មុខដាច់ខាត ដើម្បីពិចារណា និងកំណត់ថាតើការជួញដូរ ឬស៊េរីនៃការជួញដូរណាមួយត្រូវចាត់ទុកថាជាការជួញដូរខុសប្រក្រតីដូចចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ទោះជាអតិថិជនបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្ត (២)ក្រុមហ៊ុនត្រូវមានសិទ្ធិជាឯកតោភាគី និងផ្តាច់មុខដើម្បីបញ្ចប់ដោយឯកតោភាគី នូវផ្នែកខ្លះ ឬទាំងអស់នៃកិច្ចព្រមព្រៀងនេះ ដោយផ្អែកទៅលើការរកឃើញ ឬកើតឡើងនូវការជួញដូរខុសប្រក្រតី និងស៊េរីនៃការជួញដូរខុសប្រក្រតីទោះបាន ឬមិនបានប្រព្រឹត្ត គ្រប់គ្រង ឬដំណើរការរបស់អតិថិជន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃដល់អតិថិជន ។ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីការបញ្ចប់កិច្ចព្រមព្រៀងដោយក្រុមហ៊ុន ដូចចែងក្នុងចំណុចនេះ អតិថិជនត្រូវសហការជាមួយក្រុមហ៊ុនទៅតាមការណែនាំរបស់ក្រុមហ៊ុន ដើម្បីបញ្ចប់នីតិវិធីសំខាន់ៗក្នុងការបិទគណនីអតិថិជនជួញដូររបស់អតិថិជនដែលបានបើកក្នុងនាមអតិថិជនជាមួយ ក្រុមហ៊ុន។ ករណីមានការខកខាន ក្រុមហ៊ុនមានសិទ្ធិចាប់ផ្តើមនីតិវិធីតុលាការចំពោះអតិថិជនដោយមិនចាំបាច់ជូនដំណឹងជាមុន។ ក្រុមហ៊ុនរក្សាសិទ្ធិជាឯកតោភាគី និងផ្តាច់មុខ ក្នុងការរាយការណ៍អំពី

ការរកឃើញ ការជួញដូរខុសប្រក្រតី ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីបើកការស៊ើបអង្កេត ដោយមិនចាំបាច់ឆ្លងកាត់ការពិភាក្សាជាមួយអតិថិជនជាមុន បើសិនជាក្រុមហ៊ុនយល់ថាចាំបាច់ ឬទៅតាមការតម្រូវអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។

៧.១១. នៅពេលបញ្ចប់កិច្ចព្រមព្រៀងនេះដោយក្រុមហ៊ុន តាមសិទ្ធិជាឯកតោភាគី និងផ្តាច់មុខ ដោយយោងតាមចំណុចខាងលើនៃកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនមានសិទ្ធិលុបចោល និងបិទគណនីជួញដូរដែលទាក់ទងនឹងអតិថិជន លុបចោលការបញ្ជា ឬការទូទាត់ទាំងអស់ ឬស្ថានភាពជួញដូរណាមួយ ឬទាំងអស់ ដែលទាក់ទងទៅនឹងអតិថិជន ដែលក្នុងករណីនេះ អតិថិជនត្រូវទទួលខុសត្រូវលើការខាតបង់ កម្រៃ និងចំណាយផ្សេងៗ ដែលបង្កឡើងដោយអតិថិជន ។ ការលុបចោល ឬការបិទគណនី ជួញដូររបស់អតិថិជនដោយក្រុមហ៊ុននឹងមិនប៉ះពាល់ទៅដល់សិទ្ធិ និង/ឬកាតព្វកិច្ចនៃភាគីណាមួយដែលមានមុនពេលការលុបចោល និង/ឬការបិទគណនីជួញដូររបស់អតិថិជនទេ។

៧.១២. អតិថិជនត្រូវពិនិត្យ និងអនុវត្តតាមវិធានជួញដូរដែលកំណត់ដោយក្រុមហ៊ុន និងតាមការជូនដំណឹងរបស់ក្រុមហ៊ុនទៅអតិថិជន។

**ប្រការ ៨៖ កម្រៃជើងសា**

៨.១. អតិថិជនត្រូវបង់កម្រៃជើងសា នៅពេលដែលអតិថិជនដាក់បញ្ជាជួញដូរតាមរយៈគណនីជួញដូររបស់អតិថិជន ដែលអត្រានៃកម្រៃជើងសានោះ ដូចទៅនឹងការជូនដំណឹងដែលក្រុមហ៊ុនបានផ្តល់ឲ្យអតិថិជន។ អតិថិជន ត្រូវបង់រាល់កម្រៃជើងសាទាំងអស់ឲ្យក្រុមហ៊ុនភ្លាម នៅពេលដែលក្រុមហ៊ុនទទួលបានការបញ្ជាជួញដូរ និងអតិថិជនត្រូវបង្ហាញការយល់ព្រម និងផ្តល់សិទ្ធិឲ្យក្រុមហ៊ុនទូទាត់កម្រៃជើងសាទាំងនោះ។

៨.២. ការបង់ការប្រាក់ ឬការទូទាត់សាច់ប្រាក់សម្រាប់ការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជនត្រូវកំណត់ដោយក្រុមហ៊ុន និងត្រូវជូនដំណឹងដល់អតិថិជន។

**ប្រការ ៩៖ ការបិទការជួញដូរឧបករណ៍និស្សន្ទ**

៩.១. ក្រុមហ៊ុនអាចចាត់វិធានការចំពោះអតិថិជន ប្រសិនបើមានស្ថានភាពណាមួយដូចខាងក្រោម៖

ក. អតិថិជនបានលាក់បាំង ឬផ្តល់ព័ត៌មានមិនពិត។

ខ. អតិថិជនមិនអនុវត្តតាមប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ។

គ. ក្រុមហ៊ុនយល់ថា មានភាពចាំបាច់ក្នុងការបង្ការស្ថានភាពជួញដូរមិនប្រក្រតី ឬមានការអនុវត្តការជួញដូរឧបករណ៍និស្សន្ទមិនត្រឹមត្រូវ ឬអាចល្មើសច្បាប់។

ឃ. ក្រុមហ៊ុនអនុវត្តតាមការតម្រូវរបស់ គ.ម.ក.។

៩.២. វិធានការដែលក្រុមហ៊ុនអាចចាត់ចំពោះអតិថិជនដូចខាងក្រោម៖

ក. បិទស្ថានភាពជួញដូរណាមួយ ឬបិទស្ថានភាពជួញដូរទាំងអស់របស់អតិថិជន ក្នុងគោលបំណងទូទាត់កាតព្វកិច្ចរបស់អតិថិជន។

ខ. កាត់បន្ថយ ឬដាក់កំហិតលើការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជន។

**ប្រការ ១០៖ ផលប្រយោជន៍ និងទំនាក់ទំនង**

១០.១. ក្រុមហ៊ុន ត្រូវបញ្ជាក់រាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទក្នុងតារាង(២) ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិពាក់ព័ន្ធ។

១០.២. អតិថិជនទទួលស្គាល់ សន្យា អះអាង និងធានាចំពោះក្រុមហ៊ុនថា ក្នុងអំឡុងពេលដែលកិច្ចព្រមព្រៀងនេះនៅតែបន្ត៖

(ក) អតិថិជនមិនស្ថិតក្រោមកាតព្វកិច្ច មិនជាប់កិច្ចសន្យា ឬអ្វីផ្សេងទៀត និងមិនបានដឹងពីបណ្តឹងណាមួយ ឬកំពុងជាប់បណ្តឹងណាមួយដែលអាចរារាំងដល់ការអនុវត្តកាតព្វកិច្ច ឬតួនាទីរបស់ខ្លួនណាមួយក្រោមកិច្ចព្រមព្រៀងនេះ។

(ខ) អតិថិជនត្រូវគោរពតាម និងអនុវត្តរាល់ការអះអាងរបស់ខ្លួន ការធានា កាតព្វកិច្ច ការសន្យា ការយល់ព្រមអនុវត្ត និងការព្រមព្រៀងដូចដែលបានចែង។

(គ) រាល់ការអះអាងរបស់អតិថិជន និងការធានាផ្សេងៗដែលចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែនៅមានសុពលភាពក្នុងអំឡុងពេលនៃ កិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ ឬជិតត្រូវបានបញ្ចប់ទោះក្នុងហេតុផលណាក៏ដោយ។

(ឃ) អតិថិជនទទួលបានប្រឹក្សាយោបល់ពីក្រុមហ៊ុនក្នុងការពិចារណា និងការសម្រេចចិត្តដោយប្រុងប្រយ័ត្នលើការជួញដូរឧបករណ៍និស្សន្ទដែលសមស្របចំពោះអតិថិជនដោយផ្អែកលើបទពិសោធន៍ គោលដៅវិនិយោគ ប្រភព និងស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងកាលៈ-ទេសៈផ្សេងទៀត ដូចជាហានិភ័យផ្សេងៗ ដែលពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទក្រោមកិច្ចព្រមព្រៀងនេះ។

(ង) អតិថិជនមិនត្រូវបញ្ជាឲ្យក្រុមហ៊ុនធ្វើប្រតិបត្តិការអ្វីដែលចាត់ទុកថាជាការបំពាន ឬហាក់ដូចជាពាក់ព័ន្ធនឹងការបំពានច្បាប់ បទប្បញ្ញត្តិ ឬវិធានដែលកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ន ឬនឹងត្រូវអនុម័តក្នុងពេលអនាគត ឬសកម្មភាពណាមួយផ្ទុយពីគោលគំនិតរបស់ក្រុមហ៊ុនដែលប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន ឬសិទ្ធិរបស់ក្រុមហ៊ុនក្រោមកិច្ចព្រមព្រៀងនេះ។

(ច) ប្រាក់ចំណេញ និងតម្លៃនៃការវិនិយោគក្រោមកិច្ចព្រមព្រៀងនេះ មិនត្រូវបានធានាទេ និងអតិថិជនព្រមទទួលយករាល់ហានិភ័យដែលអាចកើតមាន។

**ប្រការ ១១៖ ការតវ៉ា**

**១១.១.** ករណីក្រុមហ៊ុន ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់ឲ្យបានច្បាស់ពីព័ត៌មានរបស់អតិថិជន និងបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។

**១១.២.** ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជនក្នុងអំឡុងពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបណ្តឹង។

**ប្រការ ១២៖ ការរក្សាការសម្ងាត់**

ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងក្របខណ្ឌផ្តល់សេវាកម្ម ស្របតាមកិច្ចព្រមព្រៀងនេះទៅឲ្យបុគ្គលណាមួយឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម៖

ក. មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជនដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលព័ត៌មានសម្ងាត់នោះ។

ខ. មានការតម្រូវពី គ.ម.ក ឬ តុលាការនៃព្រះរាជាណាចក្រកម្ពុជា។

គ. មានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ១៣៖ ការជូនដំណឹង**

**១៣.១.** រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឲ្យអតិថិជន ត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់ និងបទប្បញ្ញត្តិលើកលែងតែមានសំណើជាលាយលក្ខណ៍អក្សរផ្សេងពីនេះពីអតិថិជន។

**១៣.២.** អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗដល់ក្រុមហ៊ុននៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាសយដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

**ប្រការ ១៤៖ កិច្ចព្រមព្រៀងរួម**

រាល់បទបង្ហាញ ឬសេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀតដែលមានខ្លឹមសារផ្ទុយពីកិច្ចព្រមព្រៀងនេះ ទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់រវាងភាគីទាំងសងខាង មិនមានអានុភាពអនុវត្តឡើយ។

**ប្រការ ១៥៖ ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះធ្វើឡើងជា ០២ (ពីរ)ច្បាប់ដែលមានចុះហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ឬស្នាមមេដៃរបស់ភាគីទាំងសងខាងហើយក្រុមហ៊ុនត្រូវផ្តល់ឲ្យអតិថិជន ០១ (មួយ) ច្បាប់ភ្លាមៗ និងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

**ប្រការ ១៦៖ ការកែប្រែ**

កិច្ចព្រមព្រៀងនេះ អាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនត្រូវកែប្រែកិច្ចព្រមព្រៀងនេះ ឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលបានធ្វើវិសោធនកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ ប៉ុន្តែចំណុចផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ ត្រូវរក្សាទុក និងមានសុពលភាពដដែល។

**ប្រការ ១៧៖ ការចាត់តាំង**

(ក) អតិថិជនព្រមព្រៀងថារាល់សិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវផ្ទេរទៅឲ្យប្រតិសិទ្ធិសាកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជននៅក្នុងតារាងទី៣ ក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃទ្រព្យសម្បត្តិរបស់អតិថិជនដែលមាននៅក្នុងក្រុមហ៊ុនដែលកើតឡើងដោយប្រតិបត្តិនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្ស័យធន អសមត្ថភាព ដីកាតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងរាល់ការផ្ទេរទ្រព្យសម្បត្តិនោះ។

(ខ) អតិថិជនអាចចាត់តាំងបុគ្គលណាម្នាក់ជាលាយលក្ខណ៍អក្សរធ្វើជាអ្នកតំណាងរបស់ខ្លួនដែលមិនមានទំនាស់ផលប្រយោជន៍ តាមលិខិតផ្ទេរសិទ្ធិ ឬមធ្យោបាយផ្សេងទៀតដែលស្របច្បាប់ដើម្បីបញ្ជូនបញ្ជារបស់អតិថិជន ឬបញ្ជាផ្សេងទៀតទៅក្រុមហ៊ុន ក្នុងនាមអតិថិជនដើម្បីជួញដូរ។ អនុលោមតាមកិច្ចព្រមព្រៀងនេះ បុគ្គលដែលត្រូវបានចាត់តាំងជាអ្នកតំណាងរបស់អតិថិជន ត្រូវចែងនៅក្នុងលិខិតប្រគល់សិទ្ធិភ្ជាប់មកជាមួយ។

(គ) មុនពេលទទួលយកបញ្ជាណាមួយពីអ្នកតំណាងរបស់អតិថិជន ក្រុមហ៊ុនអាចតម្រូវឲ្យអតិថិជនផ្តល់ឲ្យក្រុមហ៊ុននូវឯកសារច្បាប់ដើម ឬឯកសារថតចម្លងដែលមានបញ្ជាក់ត្រឹមត្រូវ។

(ឃ) អតិថិជនត្រូវជូនដំណឹងមកក្រុមហ៊ុនជាលាយលក្ខណ៍អក្សរភ្លាម អំពីការដកសិទ្ធិតំណាងណាមួយមកវិញ។ ក្រុមហ៊ុននឹងធ្វើ ប្រតិបត្តិការតាមបញ្ជារបស់អតិថិជន ឬតាមបញ្ជាផ្សេងទៀត ដែលទទួលបានពីអ្នកតំណាងលុះត្រាមានការជូនដំណឹងផ្សេងពីនេះដោយអតិថិជន។

(ង) បុគ្គលដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះគ្មានសិទ្ធិអនុវត្តចំណុចណាមួយនៃកិច្ចព្រមព្រៀងនេះ។

**ប្រការ ១៨៖ ច្បាប់គ្រប់គ្រង**

កិច្ចព្រមព្រៀងនេះត្រូវស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន ។ រាល់វិវាទទាំងឡាយដែលកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងនេះ ការដោះស្រាយវិវាទត្រូវធ្វើតាមនីតិវិធីនៃការដោះស្រាយវិវាទដែលកំណត់ដោយ គ.ម.ក។ មុនពេលបញ្ជូនវិវាទទៅដោះស្រាយនៅ គ.ម.ក អតិថិជនត្រូវធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរមកក្រុមហ៊ុនជាមុនសិន ហើយក្រុមហ៊ុនត្រូវដោះស្រាយការតវ៉ាក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានការតវ៉ា។

**ប្រការ ១៩៖ ការបញ្ចប់កិច្ចព្រមព្រៀង**

ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលាដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល០៧ (ប្រាំពីរ) ថ្ងៃដល់ភាគីម្ខាងទៀត លើកលែងមានការកំណត់ផ្សេងពីនេះក្នុងចំណុចណាមួយនៃកិច្ចព្រមព្រៀងនេះ។ ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ច ព្រមព្រៀងនេះ មិនប៉ះពាល់សិទ្ធិ និងកាតព្វកិច្ច ព្រមទាំងផលប្រយោជន៍ដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗដែលមានមុនពេលបញ្ចប់ កិច្ចព្រមព្រៀងនេះ។

**ប្រការ ២០៖ កត្តាហានិភ័យ**

**២០.១.** អតិថិជនបានសិក្សាពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ និងបានយល់ដឹងពីការជួញដូរឧបករណ៍និស្សន្ទយន្តការ និងការអនុវត្តការជួញដូរ ការដាក់សាច់ប្រាក់តម្កល់ក្នុងគណនី កត្តាហានិភ័យ និងព្យសនកម្មដែលជាលទ្ធផលបណ្តាលមកពីការជួញដូរឧបករណ៍និស្សន្ទ។ អតិថិជនក៏បានយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ រួមទាំងសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភាគីនីមួយៗនៅក្នុងកិច្ច ព្រមព្រៀងនេះ។

**២០.២.** អតិថិជនយល់ដឹង និងទទួលស្គាល់ថាការជួញដូរឧបករណ៍និស្សន្ទគឺជាការជួញដូរមួយប្រភេទដែលមានហានិភ័យខ្ពស់ដោយថ្លៃមានការប្រែប្រួលលឿន។

**២០.៣.** មុនចុះហត្ថលេខាជាមួយអតិថិជន ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលទាក់ទងដោយផ្ទាល់ជាមួយអតិថិជនបានពន្យល់ពី ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះដល់អតិថិជន និងបានពន្យល់លម្អិតអំពីវិធីសាស្ត្រនៃការដាក់បញ្ជាទាំងអស់ និងហានិភ័យដែលអាចកើតមាន ពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការដាក់បញ្ជានីមួយៗដល់អតិថិជន។ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទអាចផ្តល់ជូនអតិថិជន នូវឯកសារផ្តល់ព័ត៌មានអំពីហានិភ័យ និងត្រូវពន្យល់លម្អិតអំពីហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ។ អតិថិជនអាចស្វែងរកការប្រឹក្សាយោបល់ផ្លូវច្បាប់ឯករាជ្យមុនពេលចុះកិច្ចព្រមព្រៀងនេះ ។ អតិថិជនទទួលយល់ព្រមចុះកិច្ចព្រមព្រៀងនេះដោយឆន្ទៈរបស់ខ្លួនផ្ទាល់ដោយមិនមានការបង្ខិតបង្ខំ ឬឥទ្ធិពលគៀបសង្កត់ណាមួយឡើយ ទោះបីជាមាន ឬមិនមានប្រឹក្សាយោបល់ផ្លូវច្បាប់ណាមួយក៏ដោយមុនចុះកិច្ចព្រមព្រៀងនេះ។

ភាគីនីមួយៗបានទទួលស្គាល់ និងបានយល់ដឹងទាំងស្រុងអំពីការអនុវត្ត និងផលវិបាកដែលកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងនេះ។

កិច្ចព្រមព្រៀងនេះ មានសុពលភាពចាប់ពីពេលភាគីទាំងពីរបានព្រមព្រៀងគ្នាដោយចុះហត្ថលេខា ឬស្នាមម្រាមដៃខាងក្រោម។

| **ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា (ករណីស្ថាប័ន) របស់អតិថិជន** | **ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រារបស់ក្រុមហ៊ុន** |
|---|---|
| **កាលបរិច្ឆេទ៖** ........................................................... | **កាលបរិច្ឆេទ៖** ......................................................... |

# ពាក្យស្នើសុំបើកគណនីជួញដូរឧបករណ៍និស្សន្ទ
## (សម្រាប់រូបវន្តបុគ្គល)

| | | |
|---|---|---|
| ឈ្មោះឈ្មួញជើងសាឧបករណ៍និស្សន្ទ៖.................................<br>ឈ្មោះភ្នាក់ងារជើងសាឧបករណ៍និសន្ទ៖................................. | កាលបរិច្ឆេទនៃការស្នើសុំ៖<br>.................................. | លេខគណនី៖<br>.......................... |

### ១. ព័ត៌មានអតិថិជន

ឈ្មោះអតិថិជន (នាម និងគោត្តនាម)៖.................................ជាអក្សរឡាតាំង៖ .................................

ធ្លាប់បានផ្លាស់ប្តូរឈ្មោះពីមុន៖☐ មិនធ្លាប់ ☐ ធ្លាប់ (បើធ្លាប់សូមភ្ជាប់ឯកសារបញ្ជាក់.................................)

ថ្ងៃ ខែ ឆ្នាំកំណើត៖................................. | សញ្ជាតិ៖................................. | ភេទ៖☐ ប្រុស ☐ ស្រី

លេខអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន៖..................ចេញដោយ..................កាលបរិច្ឆេទផុតសុពលភាព៖..................

អាសយដ្ឋានបច្ចុប្បន្ន៖.................................

អាសយដ្ឋានអចិន្ត្រៃយ៍៖.................................

លេខទូរស័ព្ទទំនាក់ទំនងផ្ទាល់៖.................................អ៊ីម៉ែល៖.................................

មុខរបរ/តួនាទី៖.................................ឈ្មោះទីកន្លែងធ្វើការ៖.................................ប្រភេទអាជីវកម្ម៖.................................អាសយដ្ឋានទីកន្លែងធ្វើការ៖.................................
.................................លេខទូរស័ព្ទកន្លែងធ្វើការ៖................................. រយៈពេលបម្រើការងារ៖..........

### ២. សហព័ទ្ធ

ឈ្មោះសហព័ទ្ធ (គោត្តនាម និងនាម)៖ ................................. ជាអក្សរឡាតាំង៖ .................................

ធ្លាប់បានផ្លាស់ប្តូរឈ្មោះពីមុន៖ ☐ មិនធ្លាប់ ☐ ធ្លាប់ (បើធ្លាប់សូមភ្ជាប់ឯកសារបញ្ជាក់.................................)

ថ្ងៃខែឆ្នាំកំណើត៖................................. | សញ្ជាតិ៖.................................

លេខទូរស័ព្ទទំនាក់ទំនងផ្ទាល់៖................................. អ៊ីម៉ែល៖.................................

ឈ្មោះទីកន្លែងធ្វើការ៖................................. | តួនាទី៖.................................

អាសយដ្ឋានទីកន្លែងធ្វើការ៖.................................

### ៣. កម្រិតវប្បធម៌ទូទៅ និងការយល់ដឹងពីឧបករណ៍និស្សន្ទរបស់អតិថិជន

១. កម្រិតសិក្សា៖☐ បណ្ឌិត ☐ អនុបណ្ឌិត ☐ បរិញ្ញាបត្រ ☐ ទាបជាងបរិញ្ញាបត្រ ជំនាញ៖.................................

២. ចំណេះដឹងអតិថិជនទាក់ទងនឹងឧបករណ៍និស្សន្ទ៖

☐អតិថិជនបានចូលរួមវគ្គបណ្តុះបណ្តាលទាក់ទងនឹងផលិតផលឧបករណ៍និស្សន្ទ។

☐អតិថិជនធ្លាប់/កំពុងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងផលិតផលឧបករណ៍និស្សន្ទ។

☐អតិថិជនធ្លាប់/កំពុងធ្វើការជួញដូរឧបករណ៍និស្សន្ទ។

☐អតិថិជនមិនធ្លាប់មានបទពិសោធន៍ជួញដូរឧបករណ៍និស្សន្ទទេ។

### ៤.គោលដៅនៃការវិនិយោគ

☐ ការវិនិយោគរយៈពេលខ្លី ☐ ការវិនិយោគរយៈពេលវែង ☐ ផ្សេងៗទៀត.................................

### ៥. បទពិសោធន៍វិនិយោគ

បទពិសោធន៍នៃការជួញដូរនៅក្នុងទីផ្សារហិរញ្ញវត្ថុដទៃទៀត ☐ មិនមាន ☐ មាន

| | | | |
|---|---|---|---|
| ១. ឈ្មោះទីផ្សារ៖..................... | ប្រភេទផលិតផល៖.................. | ប្រទេស......................... | ឆ្នាំនៃការវិនិយោគ៖..........ឆ្នាំ |
| ២. ឈ្មោះទីផ្សារ៖..................... | ប្រភេទផលិតផល៖.................. | ប្រទេស៖......................... | ឆ្នាំនៃការវិនិយោគ៖..........ឆ្នាំ |

### ៦. ចំណូលប្រចាំខែ

ចំណូលប្រចាំខែ៖ ☐ មិនមាន ☐ មាន

ចំណូលប្រចាំខែបន្ទាប់ពីដកពន្ធ

☐ 0 – ១.000.000 រៀល ឬ (0 - ២៥0 ដុល្លារអាមេរិក)
☐១.000.00១ – ២.000.000 រៀល ឬ (២៥0 - ៥00 ដុល្លារអាមេរិក)
☐ ២.000.00១ – ៣.000.000 រៀល ឬ (៥00 - ៧៥0 ដុល្លារអាមេរិក)
☐៣.000.00១ – ៤.000.000 រៀល ឬ (៧៥0- ១.000 ដុល្លារអាមេរិក)
☐ ច្រើនជាង ៤.000.00១ រៀល ឬ (១.000 ដុល្លារអាមេរិក)

ប្រភពចំណូលផ្សេងទៀត ប្រសិនបើមាន

☐ភាគលាភ/ការប្រាក់ពីមូលបត្រកម្មសិទ្ធិ/សញ្ញាបណ្ណ
☐ភាគលាភ/ការប្រាក់ពីក្រុមហ៊ុនផ្ទាល់ខ្លួន
☐ការប្រាក់ពីធនាគារ
☐ផ្សេងទៀត .................................

## ៧. វិនិយោគិនគុណវុឌ្ឍិ

តើអតិថិជនជាវិនិយោគិនគុណវុឌ្ឍិដែរ ឬទេ? ☐ មិនមែន ☐ មែន

បើមែន សូមបញ្ជាក់៖

☐ អតិថិជនមានទ្រព្យសកម្មសុទ្ធសរុបយ៉ាងតិច ១.០០០.០០០.០០០ រៀល ឬ (២៥០.០០០ ដុល្លារអាមេរិក) ឬ

☐ អតិថិជនមានចំណូលប្រចាំឆ្នាំយ៉ាងតិច ៨០.០០០.០០០ រៀល ឬ (២០.០០០ ដុល្លារអាមេរិក) ឬ

☐ អតិថិជនធ្លាប់បានចូលរួមវិនិយោគក្នុងវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច ១០០.០០០.០០០ រៀល ឬ (២៥.០០០ ដុល្លារអាមេរិក)

## ៨. បុគ្គលជាប់ទាក់ទង (សូមភ្ជាប់លេខអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន ថតចម្លងរបស់បុគ្គលជាប់ទាក់ទងនោះ)

បុគ្គលទទួលបានការអនុញ្ញាត ☐ គ្មាន ☐ មាន (សូមបញ្ជាក់គោត្តនាម និងនាម)៖ ..........................................................................................................

ទំនាក់ទំនងរវាងបុគ្គលទទួលបានការអនុញ្ញាត និងម្ចាស់គណនី៖ ..........................................................................................................

បុគ្គលទទួលបានផលប្រយោជន៍ (Beneficial Owner)៖ ☐ ផ្ទាល់ខ្លួន ☐ បុគ្គលផ្សេង (សូមបញ្ជាក់គោត្តនាម និងនាម)៖..........................................................

បុគ្គលគ្រប់គ្រង (Controlling Person)៖ ☐ ផ្ទាល់ខ្លួន ☐ បុគ្គលផ្សេង(សូមបញ្ជាក់នាមនិង គោត្តនាម)៖ ..........................................................

## ៩. កំណត់ត្រាការសម្អាតប្រាក់ក្នុងរយៈពេលបីឆ្នាំចុងក្រោយ

☐ មិនមាន ☐ មាន (បើមានសូមបញ្ជាក់លម្អិត)៖ ..........................................................................................................

## ១០. មធ្យោបាយទំនាក់ទំនងករណីមានម៉ាជីនខល

☐ លេខទូរស័ព្ទ៖............................................................................... ☐ ផ្ញើសារ៖..........................................................................................

☐ ទូរសារ៖...................................................................................... ☐ អ៊ីម៉ែល៖..........................................................................................

☐ ផ្សេងៗ៖..........................................................................................................................................................................

## ១១. ទំនាក់ទំនងរបស់អតិថិជន

១. តើអតិថិជនមានទំនាក់ទំនងជាមួយនឹងអភិបាល ឬនិយោជិតរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទដែរឬទេ?

☐ មិនមាន ☐ មាន (ឈ្មោះអភិបាល ឬនិយោជិត៖ ...................................................ត្រូវជា៖.........................................)

២. តើអតិថិជនមានទំនាក់ទំនងជាមួយនឹងអភិបាល ឬនិយោជិតរបស់សមភាគីកណ្តាលដែលឈ្មួញជើងសាឧបករណ៍និស្សន្ទជាភ្នាក់ងារទេ?

☐ មិនមាន

☐ មាន (ឈ្មោះអភិបាល ឬនិយោជិត៖.........................................ត្រូវជា៖...............................ឈ្មោះក្រុមហ៊ុនសមភាគីកណ្តាល ........................)

## ១២. ឯកសារភ្ជាប់សម្រាប់ការស្នើសុំបើកគណនី

☐ អត្តសញ្ញាណប័ណ្ណថតចម្លង ☐ សៀវភៅគ្រួសារថតចម្លង

☐ លិខិតឆ្លងដែន ឬទិដ្ឋាការថតចម្លង ☐ ផ្សេងៗ៖..........................................................

## ១៣.បុគ្គលដែលអាចទាក់ទងក្នុងករណីចាំបាច់

គោត្តនាម និងនាម៖.........................................................ជាអក្សរឡាតាំង៖..............................................................ត្រូវជា៖..........................

អាសយដ្ឋាន៖..........................................................................................................................................................................

លេខទូរស័ព្ទ៖ ............................................................................................ អ៊ីម៉ែល៖..........................................................................

## ១៤. យោបល់របស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ

..........................................................................................................................................................................................

..........................................................................................................................................................................................

ខ្ញុំសូមធានាថាព័ត៌មានដែលខ្ញុំបានផ្តល់ជូនខាងលើនេះ គឺជាព័ត៌មានដែលពិតប្រាកដ និងត្រឹមត្រូវទាំងស្រុង។ ខ្ញុំសូមសន្យាថានឹងទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយដែលផ្តល់ជូនជាព័ត៌មានមិនពិត ឬនាំឲ្យយល់ខុស។ នៅពេលចុះហត្ថលេខានៅលើពាក្យស្នើសុំនេះ ខ្ញុំបានយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ។ ខ្ញុំយល់ព្រមអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងការជួញដូរឧបករណ៍និស្សន្ទឲ្យបានខ្ជាប់ខ្ជួន និងយល់ព្រមឲ្យក្រុមហ៊ុនត្រួតពិនិត្យ និងបង្ហាញព័ត៌មានរបស់ខ្ញុំទៅ គ.ម.ក. ក្រុមហ៊ុនសមភាគីកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ច។

| ហត្ថលេខា<br>របស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ | ហត្ថលេខា<br>របស់អ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ<br>និងត្រាឈ្មួញជើងសាឧបករណ៍និស្សន្ទ | ហត្ថលេខា ឬស្នាមម្រាមដៃ<br>របស់អតិថិជន |
|---|---|---|
| កាលបរិច្ឆេទ៖................................. | កាលបរិច្ឆេទ៖..................................... | កាលបរិច្ឆេទ៖..................................... |

## តារាងទី១
## លាភការ
## ការកំណត់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ

| ប្រភេទកម្រៃ | ចំនួនប្រាក់ | ការគណនា |
|---|---|---|
| កម្រៃជើងសារ៖ | | |
| ថ្លៃសេវា៖ | | |
| លាភការផ្សេងៗ៖ | | |

| ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា (ករណីស្ថាប័ន) របស់អតិថិជន | ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រារបស់ក្រុមហ៊ុន |
|---|---|
| កាលបរិច្ឆេទ៖ ........................................ | កាលបរិច្ឆេទ៖ ............................................... |

## តារាងទី២
## ផលប្រយោជន៍ និងទំនាក់ទំនង

| ឈ្មោះ | ទំនាក់ទំនងជាមួយក្រុមហ៊ុន | ការពន្យល់ពីឥទ្ធិពល |
|---|---|---|
| | | |
| | | |
| | | |

| ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា (ករណីស្ថាប័ន) របស់អតិថិជន | ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រារបស់ក្រុមហ៊ុន |
|---|---|
| កាលបរិច្ឆេទ៖ ............................................................. | កាលបរិច្ឆេទ៖ ............................................................. |

## តារាងទី៣
## អ្នកតំណាងរបស់អតិថិជន

| ឈ្មោះអ្នកតំណាង | អាសយដ្ឋាននិងលេខទំនាក់ទំនង | ទំហំនៃការអនុញ្ញាតសិទ្ធិ |
|---|---|---|
| | | |
| | | |
| | | |

# សេចក្តីប្រកាសទទួលស្គាល់ហានិភ័យ

សេចក្តីប្រកាសទទួលស្គាល់ហានិភ័យនេះមិនបង្ហាញនូវហានិភ័យទាំងអស់ ដែលអាចកើតមានពីប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទនោះទេ។ ការធ្វើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទអាចប្រឈមនឹងហានិភ័យខ្ពស់ និងមានភាពស្មុគស្មាញច្រើន ដូចនេះអតិថិជនត្រូវពិចារណាលើប្រភេទឧបករណ៍និស្សន្ទ បទពិសោធន៍ និង ប្រភពហិរញ្ញវត្ថុរបស់អតិថិជនផ្ទាល់ ដើម្បីបញ្ជាក់ថា អតិថិជនអាចធ្វើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទបាន។ ទោះបីជាអតិថិជនធ្លាប់មានបទពិសោធន៍ក្នុងការជួញដូរឧបករណ៍និស្សន្ទក៏ដោយ ក៏អតិថិជននៅតែត្រូវយល់ដឹងអំពីហានិភ័យចម្បងៗដូចខាងក្រោម៖

**១. ឥទ្ធិពលនៃឡេវើរ៉េច** (Effect of Leverage)

មុននឹងអាចជួញដូរឧបករណ៍និស្សន្ទបាន ឈ្មួញជើងសាឧបករណ៍និស្សន្ទតម្រូវឲ្យអតិថិជនដាក់សាច់ប្រាក់តម្កល់ ដែលត្រូវបានគេហៅថាម៉ាជីនដំបូង។ ម៉ាជីនដំបូងនេះមានទំហំតូចធៀបនឹងតម្លៃជាក់ស្តែងនៃឧបករណ៍និស្សន្ទ ប៉ុន្តែអនុញ្ញាតឲ្យអតិថិជនអាចធ្វើការជួញដូរបានលើសពីទំហំសាច់ប្រាក់ជាក់ស្តែងដែលខ្លួនមាន តាមរយៈអានុភាពនៃឡេវើរ៉េច។ ក្នុងអំឡុងពេលជួញដូរ បម្រែបម្រួលថ្លៃឧបករណ៍និស្សន្ទនឹងប៉ះពាល់ដល់សាច់ប្រាក់តម្កល់របស់អតិថិជន ដែលអាចបង្កើតប្រាក់ចំណេញ ឬបង្កការខាតបង់ដល់អតិថិជន។ អតិថិជនអាចប្រឈមនឹងការខាតបង់ទាំងស្រុងនូវម៉ាជីនដំបូង និងសាច់ប្រាក់បន្ថែមដែលបានតម្កល់ជាមួយក្រុមហ៊ុន ដើម្បីរក្សាស្ថានភាពជួញដូររបស់ខ្លួន។

ក្នុងករណីកម្រិតម៉ាជីនរបស់អតិថិជនទាបជាងម៉ាជីនរក្សា អតិថិជននឹងទទួលបានម៉ាជីនខលពីឈ្មួញជើងសាឧបករណ៍និស្សន្ទ ដែលតម្រូវឲ្យអតិថិជនត្រូវដាក់សាច់ប្រាក់បំពេញបន្ថែមទៅក្នុងគណនី ក្នុងរយៈពេលជាក់លាក់មួយ ដើម្បីឲ្យកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនកើនឡើងដល់លក្ខខណ្ឌតម្រូវ។ ក្នុងករណីអតិថិជនមិនបានដាក់សាច់ប្រាក់បំពេញបន្ថែមទៅក្នុងគណនីតាមការកំណត់ អតិថិជនមិនអាចបញ្ជាទិញ-លក់ឧបករណ៍និស្សន្ទបន្ថែម ហើយរាល់ស្ថានភាពជួញដូរឧបករណ៍និស្សន្ទទាំងអស់ ឬមួយផ្នែករបស់អតិថិជនត្រូវបានបិទ ដែលអាចបង្កការខាតបង់ដល់អតិថិជន។

**២. ហានិភ័យនៃបញ្ជាបញ្ឈប់ការខាត** (Risks of Stop-Loss Order)

នៅក្នុងកាលៈទេសៈខ្លះ ដូចជាបម្រែបម្រួលថ្លៃលឿន ឬការបិទទីផ្សារ បញ្ជាបញ្ឈប់ការខាតមិនមានប្រសិទ្ធភាពនោះទេ ពោលគឺបញ្ជាបញ្ឈប់ការខាតមិនអាចការពារអតិថិជនពីការខាតបង់គ្រប់ពេលនោះទេ។

ក្នុងករណីមានភាពមិនប្រក្រតីនៃប្រព័ន្ធអេឡិចត្រូនិក បញ្ជារបស់អតិថិជនមិនអាចត្រូវបានអនុវត្ត ដែលអាចធ្វើឲ្យអតិថិជនប្រឈមនឹងហានិភ័យនៃការខាតក្នុងដាក់បញ្ជាជួញដូរឧបករណ៍និស្សន្ទ ទោះបីជាអតិថិជនបានកម្រិតទំហំខាតជាក់លាក់រួចហើយក៏ដោយ។

**៣. បម្រែបម្រួលទីផ្សារមូលដ្ឋាន** (Underlying Market Volatility)

ឧបករណ៍និស្សន្ទគឺជាឧបករណ៍ដែលអនុញ្ញាតឲ្យអតិថិជនជួញដូរលើបម្រែបម្រួលថ្លៃក្នុងទីផ្សារមូលដ្ឋាន ឬឧបករណ៍មូលដ្ឋាន។ ទោះបីជាថ្លៃឧបករណ៍និស្សន្ទត្រូវបានផ្តល់ដោយក្រុមហ៊ុនសមាគីកណ្តាលក៏ដោយ ក៏ថ្លៃនោះកើតចេញពីទីផ្សារមូលដ្ឋាន ឬឧបករណ៍មូលដ្ឋាន។ ដូចនេះអតិថិជនត្រូវយល់ថា បម្រែបម្រួលទីផ្សារមូលដ្ឋាន អាចជះឥទ្ធិពលលើថ្លៃឧបករណ៍និស្សន្ទ និងប្រាក់ចំណេញរបស់អតិថិជន។

អតិថិជនគួរយល់ដឹងផងដែរអំពីគម្លាតនៃព្រឹត្តិការណ៍ដែលអាចបង្កើតប្រាក់ចំណេញ ឬបណ្តាលឲ្យខាតនៅក្នុងគណនីអតិថិជន។ គម្លាតនៃព្រឹត្តិការណ៍អាចកើតឡើងនៅពេលទីផ្សារមូលដ្ឋានបើក ឬបិទ។ អតិថិជនត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីតាមដានការវិនិយោគរបស់ខ្លួនឲ្យបានទៀងទាត់។

**៤. ការផ្អាក ឬការដាក់កំហិតនៃការជួញដូរ** (Suspension or Restriction of Trading)

លក្ខខណ្ឌអសន្ទនីយភាពទីផ្សារ ឬការអនុវត្តនៃវិធាននៃទីផ្សារមួយចំនួន អាចបង្កើនហានិភ័យនៃការខាត ដោយសារមានការលំបាក ឬមិនអាចធ្វើប្រតិបត្តិការទូទាត់ឬការកាត់កងស្ថានភាពជួញដូរបាន។

**៥. សាច់ប្រាក់តម្កល់** (Deposited Cash)

អតិថិជនត្រូវប្រាកដថា សាច់ប្រាក់ដែលខ្លួនបានដាក់តម្កល់សម្រាប់ប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ តាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវ បានរក្សាទុកនៅក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដែល ទទួលបានការទទួលស្គាល់ពី គ.ម.ក.។ អតិថិជនត្រូវយល់ដឹងថា ការដាក់តម្កល់សាច់ប្រាក់សម្រាប់ប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទនៅកន្លែងផ្សេង ជាអំពើផ្ទុយពីបទប្បញ្ញត្តិ និង ប្រឈម នូវហានិភ័យខ្ពស់។

**៦. កម្រៃជើងសា កម្រៃសេវា និងចំនាយផ្សេងៗ (Commission, Fees and other Charges)**

មុនធ្វើការជួញដូរ អតិថិជនត្រូវទទួលបានការពន្យល់ច្បាស់លាស់អំពីកម្រៃជើងសា កម្រៃសេវា ការប្រាក់ឆ្លងថ្ងៃ (Swap) និងចំណាយផ្សេងៗ ដែលអតិថិជនត្រូវទទួលបន្ទុក។ ចំនាយទាំងនេះនឹងប៉ះពាល់ដល់ប្រាក់ចំណេញសុទ្ធ ឬកំណើននៃការខាតរបស់អតិថិជន។

**៧. ហានិភ័យរូបិយប័ណ្ណ (Currency Risks)**

ប្រតិបត្តិការជួញដូរជារូបិយប័ណ្ណបរទេសនឹងប៉ះពាល់ដល់ការចំណេញ ឬខាតរបស់អតិថិជន ដោយសារបម្រែបម្រួលនៃអត្រាប្តូរប្រាក់ ដែលតម្រូវឲ្យប្តូរពីរូបិយប័ណ្ណបរទេសនោះទៅជារូបិយប័ណ្ណផ្សេងទៀត។

**៨. ហានិភ័យសន្ទនីយភាព (Liquidity Risks)**

ឧបករណ៍និស្សន្ទខ្លះអាចមានកម្រិតសន្ទនីយភាពទាប ឬមិនមានសន្ទនីយភាព ដោយសារការថយចុះនៃតម្រូវការដែលធ្វើឲ្យអតិថិជនមិនអាចលក់ឧបករណ៍និស្សន្ទនោះ ឬមិនអាចទទួលបានព័ត៌មានអំពីថ្លៃឧបករណ៍និស្សន្ទនោះ ឬហានិភ័យពាក់ព័ន្ធដោយងាយស្រួល។

**៩. ហានិភ័យនៃការអនុវត្តបញ្ជា (Execution Risks)**

ហានិភ័យនេះអាចកើតឡើងក្នុងករណីដែលការអនុវត្តបញ្ជាទិញ-លក់ឧបករណ៍និស្សន្ទ មិនត្រូវបានអនុវត្តភ្លាមៗ។ ឧទាហរណ៍៖ អាចមានការពន្យារពេល ដែលអតិថិជនដាក់បញ្ជា និងពេលដែលបញ្ជាត្រូវបានអនុវត្ត។ ដូចនេះ បញ្ជាអាចមិនត្រូវបានអនុវត្តនៅក្នុងថ្លៃដែលអតិថិជនរំពឹងទុក។

ហានិភ័យ នេះក៏អាចកើតមានក្នុងករណីជួញដូរក្រោយទីផ្សារបិទផងដែរ។ អតិថិជនត្រូវដឹងថា ថ្លៃសម្រាប់ការជួញដូរអាចមានភាពខុសគ្នាពីថ្លៃបិទនៃ ឧបករណ៍មូលដ្ឋាន ពោលគឺ គម្លាតថ្លៃនៅពេលទីផ្សារបិទអាចមានទំហំធំជាងគម្លាតថ្លៃនៅពេលទីផ្សារបើក។

**១០. ហានិភ័យសមភាគី (Counterparty Risks)**

អតិថិជនត្រូវដឹងថា ការជួញដូរឧបករណ៍និស្សន្ទតាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទ គឺការជួញដូររវាងអតិថិជន និងក្រុមហ៊ុនសមភាគី កណ្តាលដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យា ដែលឈ្មួញជើងសាឧបករណ៍និស្សន្ទជាភ្នាក់ងារ។ ការណ៍នេះបញ្ជាក់ថា ក្រុមហ៊ុនសមភាគីកណ្តាលគឺជាសមភាគីរបស់អតិថិជននៅក្នុងប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ។ ដូចនេះ មុនពេលធ្វើប្រតិបត្តិការជួញដូរ អតិថិជនត្រូវស្វែងយល់អំពីអាជ្ញាបណ្ណវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ និងព័ត៌មានសំខាន់ផ្សេងទៀតរបស់ក្រុមហ៊ុនសមភាគីកណ្តាល ដែលឈ្មួញជើងសាឧបករណ៍និស្សន្ទបានតភ្ជាប់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទ ជាមួយ និង បទប្បញ្ញត្តិពាក់ព័ន្ធ ដែលអាចសម្រួលដល់អតិថិជនក្នុនការធ្វើប្រតិបត្តិការជួញដូរ និងកាត់បន្ថយនូវ ហានិភ័យដែលអាចកើតមាន។

**១១. ការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Trading)**

សម្រាប់ការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិក អតិថិជនអាចប្រឈមនឹងហានិភ័យទាក់ទងនឹងប្រព័ន្ធជួញដូរដែលអាចមានការខូចផ្នែករឹង (Hardware) និង/ឬ ផ្នែកទន់ (Software)។ ការខូចផ្នែកណាមួយនៃប្រព័ន្ធជួញដូរបញ្ជាទិញ-លក់របស់អតិថិជនអាចមិនត្រូវបានអនុវត្តតាមការដាក់បញ្ជា ឬមិនត្រូវបាន អនុវត្តទាំងស្រុង។ ក្នុងករណីនេះ អតិថិជនត្រូវបញ្ជាក់ជាមួយក្រុមហ៊ុនដើម្បីដោះស្រាយ។

ខ្ញុំសូមប្រកាសទទួលស្គាល់ថា បានទទួលការពន្យល់ពីភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ និងយល់ដឹងអំពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ។

| សម្រាប់អតិថិជនជារូបវន្តបុគ្គល | សម្រាប់អតិថិជនជានីតិបុគ្គល |
|---|---|
| ហត្ថលេខា ឈ្មោះរបស់អតិថិជន និងកាលបរិច្ឆេទ | ហត្ថលេខា ឈ្មោះរបស់តំណាងក្រុមហ៊ុន<br>ឈ្មោះរបស់ក្រុមហ៊ុន ត្រា និងកាលបរិច្ឆេទ |